00808954

E176/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 05 / 2012
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens
Chambre de première instance

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

សំណុំរឿងលេខ:00២/១៩ កញ្ញា ២00៧/អវតក/អជសង
Case File/Dossier N° 002/19-09-2007/ECCC/TC

ចំពោះមុខ:
ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម **Silvia CARTWRIGHT**
ចៅក្រម **យ៉ា សុខន**
ចៅក្រម **Jean-Marc LAVERGNE**
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew CAYLEY

**<u>ជនជាប់ចោទ</u>**
នួន ជា
អៀង សារី
ខៀវ សំផន

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**<u>មេធាវីជនជាប់ចោទ</u>**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់មេធាវីការពារជនជាប់ចោទ នួន ជា ចុះថ្ងៃទី ២២ ខែ កុម្ភៈ និងថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ ស្នើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយអនុលោមតាមវិធាន ៣៥[1] នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

## ២. ប្រវត្តិនីតិវិធី

២. ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះកាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារជនជាប់ចោទ នួន ជា បានយោងទៅលើសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រីនៅក្នុងសារព័ត៌មានវៀតណាម ("សេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់") និងបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ថ្កោលទោសជាផ្លូវការចំពោះសេចក្តីថ្លែងការណ៍ទាំងនោះ [...] និងស្នើឱ្យនាយករដ្ឋមន្ត្រីបញ្ឈប់ការធ្វើសេចក្តីថ្លែងការណ៍បែបនេះតទៅទៀត"[2]។ ជាការឆ្លើយតបសហព្រះរាជអាជ្ញារងអន្តរជាតិបានគូសបញ្ជាក់ថា ភាគីព្រះរាជអាជ្ញាមាន "ទំនុកចិត្តខ្ពស់" ដែលថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនអនុញ្ញាតឱ្យសេចក្តីថ្លែងការណ៍នោះជ្រៀតជ្រែកចូលក្នុងកិច្ចការរបស់ខ្លួនក្នុងការផ្តល់សំអាងហេតុដោយផ្អែកទៅលើភស្តុតាងឡើយ[3]។

៣. ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះកាលពីថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារជនជាប់ចោទ នួន ជា បានលើកម្តងទៀតនូវសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ និងបានលើកសំណើរបស់ខ្លួនម្តងទៀត ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ចាត់វិធានការដើម្បី

---

[1] សំណើសុំឱ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹង ហ៊ុន សែន អនុលោមតាមវិធាន ៣៥, ឯកសារ E176, ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សំណើលើកទីមួយ"); ប្រតិចារឹក, ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, កថាខណ្ឌ ៨០-៨១ ("សំណើលើកទីពីរ")។

[2] ប្រតិចារឹក, ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ១-៣។

[3] ប្រតិចារឹក, ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៧។

ថ្កោលទោសសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី” និង“ស្នើឱ្យ [សម្តេចនាយករដ្ឋមន្ត្រី] បញ្ឈប់ការធ្វើសេចក្តីថ្លែងការណ៍បែបនេះតទៅទៀត”[4]។ ប្រធានអង្គជំនុំជម្រះបានជម្រាបទៅមេធាវីការពារជនជាប់ចោទ នួន ជា ថា អង្គជំនុំជម្រះបានកត់សម្គាល់សំណើរបស់មេធាវីការពារក្តីរួចហើយ និងបានស្នើឱ្យមេធាវីការពារក្តីឈប់លើកបញ្ហាច្រំដែលនេះតទៅទៀត[5]។

៤. កាលពីថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារជនជាប់ចោទ នួន ជា បានលើកឡើងអំពីសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ជាលើកទី ៣ ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងបានស្នើប្រធានអង្គជំនុំជម្រះឱ្យធ្វើការបញ្ជាក់បំភ្លឺអំពីចម្លើយតបរបស់ខ្លួន ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២[6]។ លោកស្រីចៅក្រម CARTWRIGHT បានបញ្ជាក់ជាថ្មីថា អង្គជំនុំជម្រះបានកត់សម្គាល់រួចហើយនូវសំណើរបស់មេធាវីការពារជនជាប់ចោទ នួន ជា ហើយលោកស្រីចៅក្រមបានបញ្ជាក់ថា សំណើនេះនឹងត្រូវសម្រេចនាពេលខាងមុខ[7]។

៥. កាលពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ដូចខាងក្រោមនេះ៖

> នេះជាសេចក្តីសម្រេចលើការជំទាស់របស់មេធាវីអន្តរជាតិការពារក្តី នួន ជា ទាក់ទិនទៅនឹងការធ្វើសេចក្តីអធិប្បាយជាសាធារណៈអំពីអត្ថិភាពនៃពិរុទ្ធភាពលើកូនក្តីរបស់ខ្លួន។ អង្គជំនុំជម្រះបានកត់សម្គាល់នូវការជំទាស់របស់មេធាវីការពារក្តីទៅនឹងសេចក្តីអធិប្បាយជាសាធារណៈ តាមអត្ថបទសារព័ត៌មានដោយបានចោទប្រកាន់ នួន ជា កូនក្តីរបស់ខ្លួន ថា មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលជនជាប់ចោទរូបនេះកំពុងត្រូវបានជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថា តាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ដូច្នេះការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធរបស់ជនជាប់

---

4 ប្រតិចារឹក, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ១១២-១១៣។

5 ប្រតិចារឹក, ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ទំព័រ ១១៣។

6 ប្រតិចារឹក, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ១-២។

7 ប្រតិចារឹក, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៣។

ចោទណាម្នាក់ គឺជាភារកិច្ចរបស់អង្គជំនុំជម្រះដែលនឹងត្រូវសម្រេចនៅពេលបញ្ចប់សវនាការ ដោយផ្អែកលើកិច្ចពិភាក្សាដេញដោលលើអង្គហេតុ និងភស្តុតាងនានាដែលត្រូវបានបង្ហាញនៅក្នុងសវនាការ និងផ្អែកតាមច្បាប់ជាធរមានដែលអនុវត្តនៅ អ.វ.ត.ក ប៉ុណ្ណោះ។ ដូច្នេះអង្គជំនុំជម្រះមិនយកសេចក្តីអធិប្បាយជាសាធារណៈណាមួយពាក់ព័ន្ធនឹងអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់មកពិចារណានៅពេលខ្លួនពិចារណាចេញសាលក្រមនោះឡើយ[8]។

៦. ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះកាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២[9] មេធាវីការពារជនជាប់ចោទ នួន ជា បានព្យាយាម "លើកឡើងម្តងទៀត" នូវសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់។ ប្រធានអង្គជំនុំជម្រះបានរំឭកមេធាវីការពារជនជាប់ចោទ នួន ជា ថាអង្គជំនុំជម្រះបានសម្រេចលើសំណើរបស់ខ្លួនរួចហើយ[10]។

៧. លើកចុងក្រោយ មេធាវីការពារជនជាប់ចោទ នួន ជា បានដាក់សំណើចំនួន២បន្ថែមទៀតដែលសំណើមួយត្រូវបានដាក់កាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលសហព្រះរាជអាជ្ញាបានឆ្លើយតបកាលពីថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១២[11] និងសំណើមួយទៀតដែលត្រូវបានធ្វើក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ កាលពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២[12]។

## ៣. សារណា

៨. ក្នុងការគាំទ្រសំណើលើកទីមួយ មេធាវីការពារជនជាប់ចោទ នួន ជា បានលើកយកមកបង្ហាញនូវអត្ថបទដកស្រង់ចេញពីរបាយការណ៍សារព័ត៌មានចំនួន២។ នៅក្នុងរបាយការណ៍សារព័ត៌មានទីមួយ មានសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់គឺ៖

---

[8] ប្រតិចារឹក, ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ១១៣ (សំណៅកែតម្រូវជាភាសាអង់គ្លេស)។

[9] ប្រតិចារឹក, ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤។

[10] ប្រតិចារឹក, ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤។

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យសុំរបស់ នួន ជា ដែលស្នើឲ្យមានចំណាត់ការជាបន្ទាន់ប្រឆាំងនឹងនាយករដ្ឋមន្ត្រី ហ៊ុន សែន, ឯកសារ E176/1, ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១២ ("ចម្លើយតប")។

[12] ប្រតិចារឹក, ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១០, កថាខណ្ឌ ៨០-៨១។

សេចក្តីអធិប្បាយចោទប្រកាន់ដោយមេដឹកនាំខ្មែរក្រហមនៅឯសវនាការកាត់សេចក្តីកាលពីខែកន្លងទៅ ដែលថា ប្រទេសវៀតណាមបានឈ្លានពានប្រទេសកម្ពុជានៅទសវត្សរ៍ឆ្នាំ១៩៧០ នោះ សម្តេច ហ៊ុន សែន បានមានប្រសាសន៍ថា វាមិនចាំបាច់ឆ្លើយតបទៅនឹងពាក្យសម្តី "បោកប្រាស់ហ្នឹងទេ"។ ឃាតករ និងជនដែលដល់នៃអំពើប្រល័យពូជសាសន៍កំពុងតែការពារខ្លួន ដែលជាកិច្ចប្រឹងប្រែងមួយដើម្បីគេចពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម។ គេគ្រប់គ្នាដឹងថា ប្រទេសរបស់យើងធ្លាប់មានរបបប្រល័យពូជសាសន៍ ហើយឥឡូវនេះយើង និងពិភពលោក បានកំពុងដំណើរការកាត់ទោសពួកគេ"[13]។

៩. របាយការណ៍សារព័ត៌មានទីពីរហាក់ដូចជាមានចម្លើយតបពីសម្តេចនាយករដ្ឋមន្ត្រី៖

"ខ្ញុំចង់ធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈអំពីមេធាវីការពារក្តីបងធំទី២ ដែលចង់ប្តឹងខ្ញុំ" ដែលសូមឱ្យមានការឆ្លើយតបពីទីស្តីការគណៈរដ្ឋមន្ត្រី សុខ អាន។ "ខ្ញុំត្រូវបានគេសួរនៅប្រទេសវៀតណាមអំពីឧក្រិដ្ឋកម្មនៅក្នុងសម័យខ្មែរក្រហម ក៏ប៉ុន្តែមេធាវីការពារក្តីរបស់លោក នួន ជា ចោទខ្ញុំអំពីការជ្រៀតជ្រែកក្នុងកិច្ចការតុលាការ។ "សេចក្តីថ្លែងការណ៍របស់ខ្ញុំអំពី ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី គឺមិនមានឥទ្ធិពលអ្វីលើតុលាការក្នុងពេលនេះទេ"។

[...]

"តុលាការអាចធ្វើអ្វីបានតាមខ្លួនចង់ *ក៏ប៉ុន្តែខ្ញុំមានសិទ្ធិថ្កោលទោសមេដឹកនាំខ្មែរក្រហម*"[14]។

១០. មេធាវីការពារជនជាប់ចោទ នួន ជា អះអាងថា អង្គជំនុំជម្រះសាលាដំបូងពុំទាន់ចាត់ការលើសំណើរបស់ខ្លួនដែលបានធ្វើដោយផ្ទាល់មាត់ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅឡើយ ថ្វីបើមានសេចក្តីសម្រេចផ្ទាល់មាត់ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ ក៏ដោយ[15]។ មេធាវីការពារជនជាប់ចោទ នួន ជា បានលើកអំណះអំណាងថា សេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់គឺជាការប៉ុនប៉ងរបស់នាយករដ្ឋមន្ត្រី ដើម្បីដាក់ឥទ្ធិពលមកលើអង្គជំនុំជម្រះ

---

[13] សំណើលើកទីមួយ, កថាខណ្ឌ ២ *ដែលបានលើក* "Minh Nam, Tan Tu និង An Dien, "វៀតណាមពុំបានឈ្លានពានកម្ពុជា ប៉ុន្តែបានសង្គ្រោះប្រទេសកម្ពុជាទៅវិញទេ៖ ហ៊ុន សែន", Than Nien News/Vietweek, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២"។

[14] សំណើលើកទីមួយ, កថាខណ្ឌ ៦, *ដែលបានលើកឡើងថា* "ហ៊ុន សែន អំពាវនាវឱ្យមានការឆ្លើយតបពីរដ្ឋាភិបាលទៅនឹងការចោទប្រកាន់របស់មេធាវីការពារជនជាប់ចោទ នួន ជា, The Cambodia Herald, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១២។

[15] សំណើលើកទីមួយ, កថាខណ្ឌ ១៦ និងកថាខណ្ឌ ២១។

សាលាដំបូងនៅក្នុងការចេញសាលក្រមលើសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ នួន ជា[16]។ ដូច្នេះ មេធាវីការពារជនជាប់ចោទ នួន ជា អះអាងថា យោងតាមយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប សេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ រំលោភលើសិទ្ធិរបស់ជនជាប់-ចោទ នួន ជា ក្នុងការទទួលបាននូវការសន្មតថាគ្មានទោស និងសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌[17]។

១១. មេធាវីការពារជនជាប់ចោទ នួន ជា អះអាងថា ការរំលោភនេះតម្រូវឱ្យមានការដោះស្រាយជាក់ស្តែងប្រកបដោយប្រសិទ្ធភាព ហើយលើកឡើងថា ដំណោះស្រាយសមរម្យគឺថាអង្គជំនុំ-ជម្រះសាលាដំបូងត្រូវថ្កោលទោសជាសាធារណៈ នូវសេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី និងចេញ "សេចក្តីព្រមានជាសាធារណៈមួយថា ការធ្វើអត្ថាធិប្បាយណាមួយនៅពេលខាងមុខនឹងត្រូវចាត់វិធានការកាន់តែតឹងរ៉ឹងថែមទៀត"[18]។

១២. មេធាវីការពារជនជាប់ចោទ នួន ជា ស្នើមកអង្គជំនុំជម្រះសាលាដំបូងសុំឱ្យទទួលយកសំណើនេះទទួលស្គាល់ថា សេចក្តីថ្លែងការណ៍របស់សម្តេចនាយករដ្ឋមន្ត្រី គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ នួន ជា ក្នុងការទទួលបាននូវការសន្មតថាគ្មានទោស និងទង្វើបែបនេះគឺជាការជ្រៀតជ្រែកមកលើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនៅ អ.វ.ត.ក និងថ្កោលទោសជាសាធារណៈដល់សម្តេចនាយករដ្ឋមន្ត្រី និងរំឭកជាផ្លូវការកុំឱ្យគាត់ធ្វើសេចក្តីថ្លែងការណ៍ដូចគ្នាក្នុងពេលខាងមុខទៀត[19]។

១៣. ជាការឆ្លើយតប សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះបានចាត់ការរួចហើយទៅលើអង្គសេចក្តីនៃសំណើលើកទីមួយ តាមរយៈសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួន ចុះថ្ងៃទី ០២ ខែ

[16] សំណើលើកទីមួយ, កថាខណ្ឌ ១៩។

[17] សំណើលើកទីមួយ, កថាខណ្ឌ ១៧ និងកថាខណ្ឌ ២០។

[18] សំណើលើកទីមួយ, កថាខណ្ឌ ២២-២៣។

[19] សំណើលើកទីមួយ, កថាខណ្ឌ ២៤។

កុម្ភៈ ឆ្នាំ ២០១២ ហើយសំណើលើកទីមួយនេះគឺជាការដាក់សំណើច្រំដែល តែប៉ុណ្ណោះ[20]។ សហព្រះរាជអាជ្ញាអះអាងថា បញ្ហាដែលថា តើសេចក្ដីសម្រេចផ្ទាល់មាត់នេះមានលក្ខណៈគ្រប់គ្រាន់ដែរ ឬយ៉ាងណា គឺជាបញ្ហាដែលត្រូវលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ១០៤ នៃវិធានផ្ទៃក្នុង ។ ហេតុដូច្នេះ សំណើលើកទីមួយនេះមិនអាចទទួលយកបានទេ[21]។

១៤. ម្យ៉ាងទៀត សហព្រះរាជអាជ្ញាលើកអំណះអំណាងថា សេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ ពុំមែនជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះឡើយ ដោយហេតុថា អង្គជំនុំជម្រះអាចទប់ទល់នឹងសម្ពាធខាងក្រៅ និង "មិនយកចិត្តទុកដាក់ចំពោះសេចក្ដីថ្លែងការណ៍របស់សម្ដេចនាយករដ្ឋមន្ត្រីទេ"[22]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាលើកឡើងថា ផលប៉ះពាល់នៃសេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ ដែលមានទៅលើមតិសាធារណៈនៅមានកម្រិតតិចតួច ដោយហេតុថា សម្ដេចនាយករដ្ឋមន្ត្រីបានពិភាក្សាអំពីហេតុការណ៍ប្រវត្តិសាស្ត្រ និងពុំមានសិទ្ធិអំណាចណាមួយលើ អ.វ.ត.ក ឡើយ ហើយទង្វើរបស់មេធាវីការពារជនជាប់ចោទ នួន ជា ក្នុងការផ្សព្វផ្សាយជាសាធារណៈនូវសេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់នេះ គឺជាការធ្វើឱ្យប៉ះពាល់ទៅលើមតិសាធារណៈ ហើយថា សេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់គ្រាន់តែជា "វោហារសាស្ត្រនយោបាយប៉ុណ្ណោះ"[23]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះកុំទទួលយកសំណើនេះ ឬបដិសេធសំណើនេះទាំងស្រុង[24]។

---

[20] ចម្លើយតប, កថាខណ្ឌ ៤-៥។

[21] ចម្លើយតប, កថាខណ្ឌ ៧, កថាខណ្ឌ ១០-១១។

[22] ចម្លើយតប, កថាខណ្ឌ ១៣។

[23] ចម្លើយតប, កថាខណ្ឌ ១៥-១៦។

[24] ចម្លើយតប, កថាខណ្ឌ ១៧។

១៥. ពាក់ព័ន្ធនឹងសំណើលើកទីពីរ មេធាវីការពារជនជាប់ចោទ នួន ជា ចោទប្រកាន់ថា "មានរបាយការណ៍ថា សម្តេច ហ៊ុន សែន កំពុងពិចារណាអំពីវិធានការផ្លូវច្បាប់ដើម្បីសងសឹកបុគ្គលមួយរូបដែលគាត់បានចាត់ទុកជា "សមាជិកច្រងេងច្រង៉ាងមួយរូបនៃក្រុមមេធាវីការពារជនជាប់ចោទ នួន ជា" និងស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការថ្កោលទោសទង្វើរបស់សម្តេចនាយករដ្ឋមន្ត្រី[25]។

## ៤. ច្បាប់ជាធរមាន

### <u>៤.១. គោលការណ៍នៃការសន្មតថាគ្មានទោស</u>

១៦. ជាគោលការណ៍សារវ័ន្តនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទត្រូវបានសន្មតជាមុនថាគ្មានទោស រហូតដល់តុលាការរកឃើញពិរុទ្ធភាព ។ ការសន្មតទុកជាមុននេះ គឺជាធាតុផ្សំចាំបាច់មួយនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ គោល-ការណ៍នេះមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦(២) នៃកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងមាត្រា ៧(១)(ខ) នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន។

១៧. តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចជាច្រើនលើកនូវការរំលោភលើមាត្រា ៦(២) នៃកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្សក្នុងកាលៈទេសៈដែលមន្ត្រីនានាបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈពាក់ព័ន្ធនឹងជនត្រូវចោទពីបទឧក្រិដ្ឋ ដែលសេចក្តីថ្លែងការណ៍នោះបានឆ្លុះបញ្ចាំងនូវទស្សនៈដែលថា ជនត្រូវចោទមានពិរុទ្ធ នៅពេលពិរុទ្ធភាពរបស់ជនត្រូវចោទពុំទាន់ត្រូវបាន

[25] ប្រតិចារឹក, ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ៨១។

រកឃើញដោយអនុលោមតាមច្បាប់នៅឡើយ[26]។ តុលាការខាងលើបានកត់សម្គាល់ដូចខាងក្រោមនេះ៖

> គោលការណ៍នៃការសន្មតថាគ្មានទោស [...] ពុំកំហិតត្រឹមតែជាការធានានីតិវិធីនៅក្នុងរឿងក្តីព្រហ្មទណ្ឌឡើយ។ វិសាលភាពរបស់វាទូលំទូលាយជាងនេះ និងតម្រូវថា អ្នកតំណាងឲ្យរដ្ឋ ឬអាជ្ញាធរសាធារណៈទាំងឡាយ ពុំត្រូវប្រកាសថា ជនណាម្នាក់ មានទោសចំពោះបទល្មើសណាមួយនៅមុនពេលពិរុទ្ធភាពរបស់ជននោះពុំទាន់ត្រូវបានតុលាការរកឃើញនោះឡើយ[27]។

១៨. ហេតុដូច្នេះ តាមរយៈយុត្តិសាស្ត្រអន្តរជាតិ ឃើញច្បាស់ថា ការប្រកាសណាមួយអំពីពិរុទ្ធភាពរបស់ជនត្រូវចោទពីសំណាក់មន្ត្រីសាធារណៈ នៅមុនពេលតុលាការចេញសាលក្រមគឺមិនស្របទៅនឹងគោលការណ៍នៃការសន្មតថាគ្មានទោស។

---

[26] *សំណុំរឿង Allenet de Ribemont ទល់នឹង France,* សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប (15175/89), ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥, កថាខណ្ឌ ៤១។ *សំណុំរឿង Butkevicius ទល់នឹង Lithuania,* សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប (48297/99), ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២, កថាខណ្ឌ ៤៩, សំណុំរឿង *Mokhov ទល់នឹង Russia,* សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប (28245/04), ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១០, កថាខណ្ឌ ២៩។ *សូមមើលផងដែរ Gridin ទល់នឹង Russian Federation,* គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប (ឯកសារលេខ 770/1997), ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០ (ដែលបានសម្រេចថាសេចក្តីថ្លែងការណ៍របស់មន្ត្រីសាធារណៈដែលធ្វើបុរេវិនិច្ឆ័យលទ្ធផលនៃការជំនុំជម្រះឧក្រិដ្ឋកម្មដែលកំពុងដំណើរការ គឺរំលោភលើមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) និង សំណុំរឿង *International Pen and Others (ជំនួសមុខឲ្យ Ken Saro-Wiwa Jr. and Civil Liberties Organisations) ទល់នឹង Nigeria,* គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន (ឯកសារលេខ *137/94, 154/96 និង 161/97),* ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៨ (ដោយពិចារណាទៅលើការប្រកាសជាសាធារណៈអំពីពិរុទ្ធភាពរបស់ជនជាប់ចោទពីសំណាក់តំណាងរដ្ឋាភិបាល រំលោភលើមាត្រា ៧(១)(ខ) នៃគណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន)។

[27] *សំណុំរឿង Viorel Burzo ទល់នឹង Romania,* សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប (75109/01 និង 12649/02), ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ១៥៦៖ "គោលការណ៍នៃការសន្មតថាគ្មានទោស [...] មិនកំរិតត្រឹមតែការធានាផ្នែកនីតិវិធីព្រហ្មទណ្ឌឡើយ។ ខ្លឹមសាររបស់គោលការណ៍នេះ គឺមានវិសាលភាពធំធេងជាងនេះ។ តំណាងរបស់រដ្ឋ ឬអាជ្ញាធរសាធារណៈមិនត្រូវប្រកាសថា បុគ្គលណាមួយមានពិរុទ្ធភាព មុនពេលតុលាការរកឃើញពិរុទ្ធភាពរបស់បុគ្គលនោះឡើយ"។

## ៤.២. វិធាន ៣៥ នៃវិធានផ្ទៃក្នុង

១៩. ត្រង់ផ្នែកពាក់ព័ន្ធ វិធាន ៣៥ នៃវិធានផ្ទៃក្នុងចែងថា៖

១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំង បុគ្គលដែលមានចែងដូចខាងក្រោម៖

ក) ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រម ស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

ខ) ដោយគ្មានមូលហេតុសមស្រប បុគ្គលដែលមិនគោរពតាមសេចក្ដីបង្គាប់ឱ្យ ចូលរួមក្នុងដំណើរការជម្រះក្ដី ឬមិនផ្ដល់ឯកសារ ឬភស្ដុតាងផ្សេងទៀតឱ្យ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

គ) បំផ្លាញ ឬកែក្លែងតាមមធ្យោបាយណាក៏ដោយលើឯកសារ វត្ថុតាង ឬ ភស្ដុតាងដទៃទៀតដែលស្ថិតក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ឃ) គំរាមកំហែង បំភិតបំភ័យ បង្ករបួសស្នាម ឬផ្ដល់សំណូក ឬក៏ជ្រៀតជ្រែកលើ សាក្សីណាម្នាក់ ឬលើអ្នកដែលអាចក្លាយជាសាក្សីដែលកំពុងផ្ដល់ បានផ្ដល់ ឬអាចផ្ដល់ភស្ដុតាងដល់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

ង) គំរាមកំហែង បំភិតបំភ័យ ឬសូកសំណូក ឬស្វែងរកវិធីគាបសង្កត់លើ បុគ្គល ដទៃទៀតក្នុងបំណងទប់ស្កាត់បុគ្គលនោះ មិនឱ្យអនុវត្តតាមដីកា របស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ។

ច) ជួយដោយចេតនាដើម្បីឱ្យជនត្រូវចោទ ឬជនជាប់ចោទរត់គេចពីអំណាច យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬ

ឆ) ញុះញង់ ឬប៉ុនប៉ងប្រព្រឹត្តអំពើណាមួយដូចមានចែងខាងលើ។

២. នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ មានហេតុផលជឿថាបុគ្គលណា ម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយ ដូចចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រម ស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖

ក) ចាត់ការជាមួយបញ្ហានេះជាបន្ទាន់។

ខ) ដឹកនាំការស៊ើបសួរបន្ថែមដើម្បីឱ្យដឹងប្រាកដថាតើមានមូលដ្ឋានគ្រប់គ្រាន់ សម្រាប់ចាត់ការតាមនីតិវិធី ឬ

គ) បញ្ជូនបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ឬអង្គការសហប្រជាជាតិ។

[...]

៤. ច្បាប់កម្ពុជាជាធរមានត្រូវអនុវត្តចំពោះករណីទណ្ឌកម្មនីមួយៗលើបុគ្គលណាម្នាក់ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើណាមួយ ដូចមានចែងក្នុងអនុវិធាន ១។

២០. យោងតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះដែលបានទទួលការចោទប្រកាន់អំពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អាចត្រឹមតែចាត់វិធានការដោយអនុលោមតាមវិធាននេះ តែនៅពេលណាដែលខ្លួនមានមូលហេតុអាចឱ្យជឿបានថា បុគ្គលម្នាក់អាចបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ ឧទាហរណ៍តាមរយៈការដាក់សម្ពាធដោយមិនត្រឹមត្រូវមកលើចៅក្រមដែលទទួលបន្ទុកចាត់ការរឿងក្តី[28]។ នេះជាលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់បើកការស៊ើបអង្កេត ដែលត្រូវបានជំរុញដោយ "ជំនឿសមហេតុផល" ថា អំពើដែលអាចគំរាមដល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះអាចបានកើតមាន។ អំពើនេះនាំឱ្យមានត្រឹមតែការស៊ើបអង្កេតបន្ថែម និងពុំតម្រូវឱ្យអង្គជំនុំជម្រះពិនិត្យជាលម្អិតទៅលើខ្លឹមសារនៃការចោទប្រកាន់ ឬការសង្ស័យអំពីការជ្រៀតជ្រែក ឬវាយតម្លៃអំពីបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ។ បទដ្ឋាននេះនឹងត្រូវបានបំពេញតែនៅពេលណាដែលមានមូលដ្ឋានច្បាស់លាស់សម្រាប់ការចោទប្រកាន់នេះ ហើយធ្វើឱ្យអង្គជំនុំ-

[28] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ឯកសារ D314/1/8 និង ឯកសារ D314/2/7 (សម្ងាត់), ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤០ (ដោយបានកត់សម្គាល់ថាវិធាន ៣៥ នៃវិធានផ្ទៃក្នុងស្រដៀងនឹងវិធាន ៧៧ នៃវិធាននីតិវិធី និងភស្តុតាងនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") ហើយយុត្តិសាស្ត្ររបស់តុលាការ ICTY នេះជួយដល់ការបញ្ជាក់បំភ្លឺអំពីគោលបំណង និងវិសាលភាពនៃវិធាន ៣៥) ដោយហេតុថាជាមួយវិធាន ៧៧ នៃតុលាការ ICTY កិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងគឺជាកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទើបចំណុះឱ្យគោលការណ៍ធម្មតានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ)។

ជម្រះជឿជាក់ថា ការចោទប្រកាន់នេះមិនមែនជាការចោទប្រកាន់ដោយស្មានៗនោះឡើយ[29]។ នៅពេលមានមូលហេតុអាចឲ្យជឿបានថា បុគ្គលណាម្នាក់អាចបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះ ឬ សហចៅក្រមស៊ើបអង្កេត អាចចាត់វិធានការណ៍មួយ ឬច្រើន ក្នុងចំណោមវិធានការណ៍នានា ដូចមានចែងក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង ដែលរួមមានទាំងការចាត់ការលើបញ្ហាជាបន្ទាន់ផងដែរ។

២១. ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា គោលបំណងនៃការហាមឃាត់ទង្វើនានាដែលមានចេតនាធ្វើឲ្យប៉ះពាល់កិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះគឺដើម្បីធានាថា ការអនុវត្តនូវយុត្តាធិការរបស់តុលាការពុំត្រូវបានរារាំង ហើយភារកិច្ចជាមូលដ្ឋាន

[29] សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សីឯកសារ D314/1/12, ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ៣៦ និង ៣៧ (ដែលបានពន្យល់ថាវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចែងអំពីបទដ្ឋានពាខុសគ្នានៃភស្តុតាងទាក់ទិននឹងការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ៖ (i) បទដ្ឋានទីមួយគឺ "មូលហេតុអាចឲ្យជឿបាន" (ដែលត្រូវបានទទួលស្គាល់ថាជាបទដ្ឋានអប្បបរមា) (ii) បទដ្ឋានទីពីរគឺ "មូលដ្ឋានគ្រប់គ្រាន់" និង (iii) មូលដ្ឋានទីបី គឺ "ហួសពីវិមតិសង្ស័យ"។ បទដ្ឋាន "មូលដ្ឋានគ្រប់គ្រាន់" ដូចមានចែងក្នុងវិធាន ៣៥(២)(ខ) គឺជាបុរេលក្ខខណ្ឌមួយសម្រាប់ការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនដែលត្រូវបានសង្ស័យថាបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ។ បទដ្ឋាន "ហួសពីវិមតិសង្ស័យ" ទោះបីពុំមានចែង ច្បាស់ក្នុងវិធាន ៣៥ ក៏ដោយ ក៏ជាបទដ្ឋាននៃភស្តុតាងដែលត្រូវតែបំពេញដើម្បីដាក់ទណ្ឌកម្មលើជនណាដែលបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះដោយចេតនាពិតប្រាកដ ដោយអនុលោមតាមវិធាន ៨៧(១) និងយុត្តិសាស្ត្រអន្តរជាតិ។ *សូមមើលឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Simic,* ការសម្រេចលើបញ្ហានៃការចោទប្រកាន់អំពីការប្រមាថប្រឆាំងនឹងជនជាប់ចោទ និងមេធាវីរបស់គាត់, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (លេខសំណុំរឿង IT-95-9-R77), ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០០, កថាខណ្ឌ ១០០។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងទៅនឹងដីកាសម្រេចលើសំណើលើកទីពីររបស់លោក នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរ (វិធាន ៣៥), ឯកសារ D384/5/2 (សម្ងាត់), ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១០, កថាខណ្ឌ៤៨, ៤៩។

របស់តុលាការត្រូវបានការពារ[30]។ ប្រការនេះទាមទារឱ្យមជ្ឈដ្ឋានខាងក្រៅបញ្ឈប់ការព្យាយាមដាក់ឥទ្ធិពលមកលើចៅក្រម ឬបញ្ឈប់ទង្វើដែលគេអាចចាត់ទុកជាការព្យាយាមដាក់ឥទ្ធិពលមកលើចៅក្រម។ ដោយសារតែគោលការណ៍ទាំងនេះមានសារៈសំខាន់ដល់ការបំពេញមុខងារត្រឹមត្រូវនៃស្ថាប័នតុលាការ ទើបតុលាការតែងតែបានព្យាយាមបញ្ជាក់ជាថ្មីអំពីគោលការណ៍ទាំងនេះគ្រប់ពេលវេលា នៅពេលណាដែលមានការធ្វើសេចក្តីថ្លែងការណ៍នានាដែលហាក់ដូចជារំលោភលើគោលការណ៍នៃការសន្មតថាគ្មានទោសនេះ បើទោះបីជាមិនមានបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌកើតមានឡើងក៏ដោយ។

២២. នៅពេលមានការចោទប្រកាន់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌ បទដ្ឋានសម្រាប់ការអន្តរាគមន៍ពីអង្គជំនុំជម្រះត្រូវមានកម្រិតខ្ពស់។ ត្រង់ប្រការនេះ បុគ្គលណាម្នាក់អាចត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវចំពោះការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ហើយអាចត្រូវបានដាក់ទណ្ឌកម្ម លុះត្រាតែមានភស្តុតាងបង្ហាញថា បុគ្គលនេះបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ "ដោយដឹង និងដោយចេតនាពិតប្រាកដ"ប៉ុណ្ណោះ[31]។ វិធាន ៧៧(ក) នៃតុលាការ ICTY មានបញ្ញត្តិមួយស្រដៀងនេះ ដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបកស្រាយ ដោយតម្រូវឱ្យមានការបង្ហាញអំពី "ធាតុចេតនាជាក់លាក់ក្នុងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ"[32]។ អង្គជំនុំជម្រះយល់ស្របទៅនឹងការបកស្រាយខាងលើ និងប្រកាន់យកការបកស្រាយនេះពាក់ព័ន្ធនឹងវិធាន ៣៥(១) នៃ

---

[30] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Aleksovski,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Anto Nobilo ប្រឆាំងនឹងការរកឃើញអំពីការប្រមាថ (លេខសំណុំរឿង IT-95-14/1-AR77), ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១, ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ Nobilo"), កថាខណ្ឌ ៣៦។

[31] សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីសំណើលើកទីពីររបស់ នួន ជា, កថាខណ្ឌ ៤៤ (ដោយកត់សម្គាល់ថា "ទង្វើនៃ [ការដាក់] សម្ពាធពីខាងក្រៅមកលើចៅក្រមនៃ អ.វ.ត.ក" ឬទង្វើដែលអាចត្រូវបានចាត់ទុកជាការធ្វើដូច្នោះ អាចមានតម្លៃស្មើទៅនឹងការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ក្នុងខ្លឹមសារនៃវិធាន ៣៥)។

[32] វិធាន ៣៥(១) នៃវិធានផ្ទៃក្នុង។

00808967



វិធានផ្ទៃក្នុង។ តាមសំអាងហេតុខាងក្រោម មិនមានបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌកើតមាននៅក្នុងករណីនេះទេ ដោយអនុលោមតាមអនុវិធាននេះ។ បើទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានរំឭកអំពីភាពចាំបាច់ក្នុងការគោរពនិយាមនានាដែលការពារឯករាជ្យភាពរបស់តុលាការ និងគោលការណ៍នៃការសន្មតថាគ្មានទោសដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។

## ៥. សំអាងហេតុ

### <u>៥.១. ការទទួលយកសំណើ</u>

២៣. ដោយហេតុថា គ្មានសំណើផ្ទាល់មាត់ណាមួយរបស់មេធាវីការពារជនជាប់ចោទ នួន ជា ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៅមុនថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១២ ត្រូវបានកំណត់ប្រភេទជាក់លាក់ថា ជាសំណើ ដោយអនុលោមតាមវិធាន ៣៥ ទេនោះ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា សំណើលើកទីមួយនេះ បានត្រឹមតែពង្រីកវិសាលភាពនៃសំណើផ្ទាល់មាត់មុនរបស់មេធាវីការពារជនជាប់ចោទ នួន ជា ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានសម្រេចលើសំណើនោះរួចហើយកាលពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២។ ហេតុដូច្នេះ អង្គជំនុំជម្រះឯកភាពជាមួយសហព្រះរាជអាជ្ញាដែលថា សំណើលើកទីមួយគឺជាការដាក់សំណើច្រំដែលហើយអង្គជំនុំជម្រះប្រកាសថា សំណើនេះមិនមានលក្ខណៈអាចឱ្យទទួលយកបានឡើយ[33]។ ទោះបីជាយ៉ាងនេះក៏ដោយ ដើម្បីបញ្ជាក់បំភ្លឺអំពីសេចក្តីសម្រេចដោយផ្ទាល់មាត់របស់ខ្លួនចុះ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសូមបញ្ជាក់ជាលម្អិតនូវសំអាងហេតុនៃសេចក្តីសម្រេចដើម

---

[33] *សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង* Beqaj, សេចក្តីសម្រេចលើការចោទប្រកាន់ពីបទប្រមាថ, អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY (លេខ IT-03-66-T-R77), ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥, កថាខណ្ឌ ២២, សំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Brdanin, សេចក្តីសម្រេចលើសំណើសុំលើកលែងការចោទប្រកាន់ ដោយអនុលោមតាមវិធាន ៩៨ *ស្ទួន* , អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (លេខសំណុំរឿង IT-99-36-R77), ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៤, កថាខណ្ឌ ១៦។

របស់ខ្លួន និងលើកនូវច្បាប់ជាធរមានទាក់ទិននឹងគោលការណ៍នៃការសន្មតថាគ្មានទោស ទាក់ទិននឹងសេចក្តីថ្លែងការណ៍របស់មន្ត្រីសាធារណៈ។

២៤. អង្គជំនុំជម្រះយល់ឃើញថា សំណើលើកទីពីរអាចទទួលយកបាន ក្នុងប្រភេទជាសំណើដាច់ដោយឡែកមួយ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយហេតុថាសំណើនេះត្រូវបានធ្វើឡើងដោយផ្អែកលើព័ត៌មាន ដែលមិនត្រូវបានផ្តល់ជូនដល់អង្គជំនុំជម្រះ មុនពេលមានសេចក្តីសម្រេចដោយផ្ទាល់មាត់នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ ឬ នៅក្នុងសំណើលើកទីមួយ។

## ៥.២. ការបញ្ជាក់ជាលម្អិតអំពីសេចក្តីសម្រេចចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២

២៥. យោងតាមអត្ថបទសារព័ត៌មានដែលត្រូវបានរាយការណ៍ សេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់គឺជាការអត្ថាធិប្បាយទាក់ទងនឹង "ការចោទប្រកាន់របស់អតីតមេដឹកនាំខ្មែរក្រហមមួយរូប នៅក្នុងសវនាការមួយ [កាលពីខែ ធ្នូ ឆ្នាំ ២០១១] ដែលថា វៀតណាមបានឈ្លានពានកម្ពុជាក្នុងទសវត្សរ៍ ១៩៧០"។ ក្នុងអំឡុងកិច្ចដំណើរការសវនាការកាលពីខែ ធ្នូ ឆ្នាំ ២០១១ ទាំង ជនជាប់ចោទ នួន ជា និង ខៀវ សំផន បាននិយាយអំពីវៀតណាម។ ប៉ុន្តែមានតែជនជាប់ចោទ នួន ជា ម្នាក់ប៉ុណ្ណោះ ដែលជាអ្នកបានធ្វើអត្ថាធិប្បាយនានាដែលគេអាចចាត់ទុកជាការចោទប្រកាន់អំពីការឈ្លានពានមួយក្នុងទសវត្សរ៍ ១៩៧០[34]។ ហេតុដូច្នេះហើយ សេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ហាក់ដូចជាសំដៅជាក់លាក់ទៅរកតែជនជាប់-ចោទ នួន ជា ម្នាក់ប៉ុណ្ណោះ[35]។

---

[34] ចម្លើយតប, កថាខណ្ឌ ៤។

[35] ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៤៤, ៤៦ (នួន ជា); ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ទំព័រ ៧៥, ៨០, ៨១, ៨៣ (ខៀវ សំផន)។ ទោះបី អៀង សារី បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងបានផ្តល់ភស្តុតាងនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ក៏ដោយ ក៏គាត់មិនបាននិយាយដល់ប្រទេសវៀតណាមទេ លើកលែងតែពេលដែលគាត់បញ្ជាក់ពីទីកន្លែងកំណើតរបស់ខ្លួននៅខេត្តត្រាវិញ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ

២៦. ដោយមិនចាំបាច់គិតថា សេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ ត្រូវបានរាយការណ៍ដោយត្រឹមត្រូវ ឬមិនត្រឹមត្រូវនៅក្នុងសារព័ត៌មាន ឬយ៉ាងណានោះ (ដូចដែលនឹងបញ្ជាក់ខាងក្រោម) សេចក្តីថ្លែងការណ៍បែបនេះមិនស្របជាមួយគោលការណ៍នៃការសន្មតថាគ្មានទោសដែលលោក នួន ជា មានសិទ្ធិទទួលនោះឡើយ។ ជាពិសេស ការប្រើពាក្យថា "ជាឃាតករ និង ជាជនដែលដល់នៃអំពើប្រល័យពូជសាសន៍" ដែលការណ៍នេះហាក់ដូចជាឆ្លុះបញ្ចាំងនូវទស្សនៈមួយដែលថា ជនជាប់ចោទ នួន ជា មានពិរុទ្ធភាព បើទោះបីជនជាប់ចោទ នួន ជា មិនទាន់ត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពក៏ដោយ។ ប្រសិនបើមានសេចក្តីថ្លែងការណ៍បែបនេះមែននោះ ការណ៍នេះគឺជាការធ្វើបុរេវិនិច្ឆ័យដោយមន្ត្រីសាធារណៈជាន់ខ្ពស់មួយរូបទៅលើសំណុំរឿងព្រហ្មទណ្ឌមួយដែល អ.វ.ត.ក កំពុងពិភាក្សាដេញដោលដើម្បីសម្រេចសេចក្តី ហើយក៏អាចមានឥទ្ធិពលដល់ការយល់ឃើញរបស់សាធារណៈជនទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ នួន ជា។

២៧. អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីថា សេចក្តីថ្លែងការណ៍ទាំងនេះនឹងមិនមានឥទ្ធិពលមកលើអង្គជំនុំជម្រះ ឬចៅក្រមម្នាក់ៗរបស់អង្គជំនុំជម្រះនៅក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឡើយ។ ដូចដែលអង្គជំនុំជម្រះធ្លាប់បានលើកឡើងម្តងហើយម្តងទៀតថា ចៅក្រមវិជ្ជាជីវៈនៅ អ.វ. ត.ក ត្រូវបានសន្មតថាជាបុគ្គលដែលមានសមត្ថភាពបំពេញមុខងារវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយសុចរិតភាព ឯករាជ្យភាព និងមិនលម្អៀង ដោយសំអាងទៅលើការស្បថចូលកាន់តំណែងការបណ្តុះបណ្តាល និងបទពិសោធន៍[36]។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងគឺ ជាចៅក្រម

៣-៦ និង ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៥៥-៥៧ (អៀង សារី)។ បន្ទាប់មក គាត់បានប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតប ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៥៩ (អៀង សារី)។

[36] *សូមមើល ឧទាហរណ៍* សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន លោកស្រីចៅក្រម Silvia CARTWRIGHT លោកចៅក្រម យ៉ា សុខន លោកចៅក្រម Jean-Marc LAVERGNE និងលោកចៅក្រម ធូ មណី, ឯកសារលេខ, ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ១២ (

ដែលមានសមត្ថភាពគ្រប់គ្រាន់ខាងផ្នែកច្បាប់ និងពុំទទួលរងឥទ្ធិពលពីការធ្វើអត្ថាធិប្បាយជាសាធារណៈណាមួយ ដូចសមាជិកនៃស្ថាប័នសាធារណៈដែលអាចមាននោះឡើយ។ អង្គជំនុំជម្រះនឹងពិចារណាតែលើអង្គហេតុ ភស្តុតាង សារណាទាំងអស់ដែលពាក់ព័ន្ធ និងច្បាប់ជាធរមាន នៅក្នុងក្របខ័ណ្ឌច្បាប់ដែលខ្លួនមានប៉ុណ្ណោះ ហើយមិនពិចារណាទៅលើមតិសាធារណៈនានាស្តីពីអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទណាម្នាក់នៅពេលខ្លួនពិភាក្សាចេញសាលក្រមនោះឡើយ[37]។

២៨. ដូចដែលបានបញ្ជាក់ខាងលើ និងអនុលោមតាមក្របខ័ណ្ឌច្បាប់ដែលមានចែងក្នុងវិធាន ៣៥ (២) នៃវិធានផ្ទៃក្នុង បទដ្ឋានសម្រាប់ការពិចារណាទៅលើបញ្ហានាពេលនេះ គឺថាតើមាន "មូលហេតុអាចឱ្យជឿបាន" ថា មានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ អនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ដែរ ឬយ៉ាងណា។

២៩. អង្គជំនុំជម្រះពិចារណាឃើញថា ប្រសិនបើសេចក្តីថ្លែងការណ៍ទាំងអស់នេះត្រូវបានរាយការណ៍ដោយត្រឹមត្រូវ សេចក្តីថ្លែងការណ៍នេះមានលក្ខណៈមិនស្របទៅនឹងគោលការណ៍នៃការសន្មតថាគ្មានទោសទេ។ សេចក្តីថ្លែងការណ៍ជាសាធារណៈដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងពិរុទ្ធភាពរបស់ជនជាប់ចោទ នួន ជា ដែលសម្តេចនាយករដ្ឋមន្ត្រីបានធ្វើទៅកាន់សារព័ត៌មាន អាចនាំឱ្យមានជំនឿសមហេតុផល និងបំពេញលក្ខខណ្ឌនៃបទដ្ឋាននេះ។ ដោយហេតុថា នាពេលនេះ សំណុំរឿងព្រហ្មទណ្ឌដែលមានជនជាប់ចោទ នួន ជា កំពុងរង់ចាំការសម្រេចសេចក្តីនៅ ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយបើទោះបីជាសេចក្តីថ្លែងការណ៍នេះត្រូវបានធ្វើឡើងដោយគ្មានចេតនាអ្វីមួយក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា សេចក្តីថ្លែងការណ៍នេះ មានហានិភ័យដែលអាចត្រូវបានគេយកទៅបកស្រាយថា មានការ

---

ដែលដកស្រង់ចេញពីរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Furundžija*, សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-95-17/1-A), ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២000, កថាខណ្ឌ ១៩៦)។

[37] ប្រតិចារឹក ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ២០១២, ទំព័រ ១១៣។

ប៉ុនប៉ងដាក់សម្ពាធដោយមិនសមរម្យមកលើចៅក្រមដែលកំពុងទទួលបន្ទុកចាត់ការរឿងក្ដីនេះ ។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា អង្គជំនុំជម្រះអាចចាត់វិធានការណ៍ណាមួយ ឬ មិនចាំបាច់ចាត់វិធានការណ៍ណាមួយក្នុងចំណោមវិធានការណ៍នានាដូចមានចែងក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង បើទោះបីជាសេចក្ដីថ្លែងការណ៍នេះមិនបណ្ដាលឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយអនុលោមតាមវិធាន ៣៥(១) ក៏ដោយ។

៣០. ទាក់ទិននឹងការទទួលខុសត្រូវព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ ដោយអនុលោមតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះយល់ឃើញថា មិនមានភស្ដុតាងក្នុងការបញ្ជាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ នៅក្នុងករណីនេះ។ គោលការណ៍នានាដែលមាននៅក្នុងវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រអន្តរជាតិពាក់ព័ន្ធកំណត់ថាទណ្ឌកម្មព្រហ្មទណ្ឌអាចត្រូវបានដាក់តែក្នុងករណីមានភស្ដុតាងបង្ហាញថា បុគ្គលនោះបានជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយដឹង និងដោយចេតនាពិតប្រាកដ ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានពិនិត្យឯកសារសម្ភារៈដែលមេធាវីការពារជនជាប់ចោទ នួន ជា បានលើកឡើងដើម្បីគាំទ្រសំណើរបស់ខ្លួនសុំឱ្យមានការដាក់ទណ្ឌកម្មទៅលើសម្ដេចនាយករដ្ឋមន្ត្រី។ ថ្វីត្បិតការធ្វើសេចក្ដីអត្ថាធិប្បាយណាមួយអំពីអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទ មុនពេលចេញសាលក្រម គឺជាប្រភពនៃបញ្ហាពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌគតិយុត្តជាធរមានដែលពុំអាចជៀសវាងបានក៏ដោយ ក៏ប៉ុន្តែ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បរិបទនៃការធ្វើសេចក្ដីថ្លែងការណ៍ទាំងនេះ ពុំមាននរណាដឹងច្បាស់លាស់ឡើយ ហើយសេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់នេះ ក៏មិនមានភាពច្បាស់លាស់ដែរ (ដែលក្នុងពេលដំណាលគ្នានេះ សេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់នេះ ត្រូវបានទទួលស្គាល់ថា“តុលាការអាចធ្វើអ្វីតាមខ្លួនចង់” (កថាខណ្ឌ ៩))។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ភស្ដុតាងទាំងប៉ុន្មានដែលមេធាវីការពារជនជាប់ចោទ នួន ជា បានលើកឡើងដើម្បីគាំទ្រដល់សំណើសុំឱ្យមានការដាក់ទណ្ឌកម្មនោះ ពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យមានកិច្ចស៊ើបសួរផ្នែកព្រហ្មទណ្ឌឡើយ ហើយ

វាគ្រាន់តែជាសំណើមួយដែលផ្អែកលើតែការស្មានៗប៉ុណ្ណោះ ត្រង់ចំណុចដែលសំណើចោទប្រកាន់អំពីការជ្រៀតជ្រែកដោយចេតនា ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៣៥(១)។ បើទោះបីជាបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌពុំកើតមាននៅក្នុងរឿងក្ដីនេះក៏ដោយ ក៏សេចក្ដីថ្លែងការណ៍របស់សម្ដេចនាយករដ្ឋមន្ត្រីបំពេញបទដ្ឋានអប្បបរមាសម្រាប់ការអន្តរាគមន៍ពីអង្គជំនុំជម្រះ ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ អនុលោមតាមអនុវិធាននេះ ដើម្បីផលប្រយោជន៍នៃភាគីទាំងអស់ អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីអំពីគោលការណ៍នៃឯករាជ្យភាពរបស់តុលាការ និងគោល-ការណ៍នៃការសន្មតថាគ្មានទោស ដោយធ្វើការកត់សម្គាល់អំពីសារៈសំខាន់នៃការបំពេញមុខ-ងារដោយត្រឹមត្រូវ និងជំនឿទុកចិត្តលើ អ.វ.ត.ក។

៣១. ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា វាជាការពុំចាំបាច់ដែលត្រូវបើកកិច្ចស៊ើបសួរ ដើម្បីបញ្ជាក់ពីយថាភាពនៃសេចក្ដីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់ទាំងនេះឡើយ។ តាមក្របខ័ណ្ឌគតិយុត្តនៃ អ.វ.ត.ក អង្គជំនុំជម្រះអាចជ្រើសរើសចាត់វិធានការណ៍ណាមួយ ឬពុំចាំបាច់ចាត់វិធានការណាមួយដែលជាឆន្ទានុសិទ្ធិ ដូចមានចែងក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានចេញសេចក្ដីប្រកាសយ៉ាងច្បាស់លាស់ជាសាធារណៈអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការសន្មតថាគ្មានទោស និងភាពចាំបាច់ដែលមន្ត្រីនានាគប្បីជៀសវាងការធ្វើសេចក្ដីអធិប្បាយណាមួយដែលមិនស្របទៅនឹងគោលការណ៍នេះ ដោយហេតុថា ការធ្វើសេចក្ដីអធិប្បាយបែបនេះ អាចធ្វើឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តនៃការការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅ អ.វ.ត.ក ប្រសិនបើមានសេចក្ដីអធិប្បាយម្ដងហើយម្ដងទៀតនោះ។ ស្ថិតក្នុងកាលៈទេសៈនេះ អង្គជំនុំ-ជម្រះយល់ឃើញថា ការវិំពួកនេះមានលក្ខណៈគ្រប់គ្រាន់ហើយពុំចាំបាច់ត្រូវមានវិធានការណ៍អ្វីនោះទេ ហើយក៏មិនពាក់ព័ន្ធទៅនឹងបញ្ហាណាមួយនៃអភ័យឯកសិទ្ធិដែលច្បាប់បានផ្ដល់ជូនដល់សម្ដេចនាយករដ្ឋមន្ត្រីឡើយ។

**៥.៣. អង្គសេចក្តីនៃសំណើលើកទីពីរ**

៣២. អង្គជំនុំជម្រះយល់ឃើញថា សំណើលើកទីពីរ ដែលផ្អែកទៅលើសេចក្តីថ្លែងការណ៍ដែលត្រូវបានចោទប្រកាន់របស់នាយករដ្ឋមន្ត្រី ទាក់ទងទៅនឹង "សមាជិកច្រងេងច្រង៉ាងមួយរូបនៃក្រុមមេធាវីការពារជនជាប់ចោទ នួន ជា" នោះ ពុំមានមូលដ្ឋានច្បាស់លាស់ឡើយ ដោយហេតុថា មេធាវីការពារក្តីពុំបានផ្តល់ភស្តុតាងណាមួយស្តីពីការចោទប្រកាន់នោះឡើយ។ តាមចរិតលក្ខណៈនៃសេចក្តីថ្លែងការណ៍នេះ អង្គជំនុំជម្រះជឿជាក់ថា មិនមានការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ឬ ការរំលោភលើគោលការណ៍នៃការសន្មត ថាគ្មានទោសកើតមាននោះឡើយ។

**តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**ប្រកាស** ច្រានចោលសំណើលើកទីមួយរបស់មេធាវីការពារជនជាប់ចោទ នួន ជា។

**បដិសេធ** សំណើលើកទីពីររបស់មេធាវីការពារជនជាប់ចោទ នួន ជា លើអង្គសេចក្តី។

ភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

**និល ណុន**